រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃអង្គារ៍ ទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

## កម្មករ-កម្មការិនីកាត់ដេរនឹងប្រកួតប្រជែងចំណេះដឹង ស្តីពីច្បាប់ការងារប្រទេសកម្ពុជា

ភ្នំពេញ ប្រទេសកម្ពុជា- *គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ ដោយសហការជាមួយវិទ្យុមហានគរ FM៩៣.៥ នឹងរៀបចំការប្រកួតប្រជែងតាមរលកធាតុអាកាសវិទ្យុមួយ ដោយអនុញ្ញាតឱ្យកម្មករ-កម្មការិនីកាត់ដេរក្រកួតប្រជែងចំណេះដឹងស្តីពីច្បាប់ការងាររបស់ប្រទេសកម្ពុជា។

ការប្រកួតប្រជែងតាមរលកធាតុអាកាសវិទ្យុនេះនឹងផ្តល់ឱកាសដល់កម្មករ-កម្មការិនីកាត់ដេរដើម្បីបង្ហាញពីចំណេះដឹងស្តីពីច្បាប់ការងាររបស់ប្រទេសកម្ពុជា។ ការប្រកួតប្រជែងនេះ មានគោលបំណងដើម្បីផ្សព្វផ្សាយចំណេះដឹងស្តីពីច្បាប់ការងាររបស់ប្រទេសកម្ពុជា និងលក្ខខណ្ឌការងារក្នុងឧស្សាហកម្មកាត់ដេរ ទៅដល់កម្មករ-កម្មការិនីកាត់ដេរ និងសាធារណជន ព្រមទាំងតស៊ូមតិដើម្បីឱ្យមានការអនុវត្តន៍ច្បាប់ការងារប្រកបដោយប្រសិទ្ធិភាព និងលើកកម្ពស់ឧស្សាហកម្មកាត់ដេរនេះផងដែរ។

កញ្ញា Catherine Vaillancourt-Laflamme អ្នកជំនាញផ្នែកបណ្តុះបណ្តាលរបស់*គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានប្រសាសន៍ថា "មូលដ្ឋានគ្រឹះនៃប្រព័ន្ធទំនាក់ទំនងឧស្សាហកម្មដែលជាកត្តាផ្តួបផ្តុំមួយដ៏សំខាន់ចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព គឺផ្អែកទៅលើការយល់ដឹងដ៏ទូលំទូលាយពីច្បាប់ការងារ និងពីស្ថាប័នដែលអនុវត្តច្បាប់នេះ។"

កញ្ញា Catherine Vaillancourt-Laflamme បន្តទៀតថា "ជាមួយនឹងការចូលរួមប្រកួតប្រជែងពីសំណាក់កម្មករ-កម្មការិនីកាត់ដេរនេះ *គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ចង់បង្កើនការយល់ដឹងដល់កម្មករ-កម្មការិនីស្តីពីច្បាប់ការងារ ខណៈពេលដែលគម្រោងនេះបាននឹងកំពុងលើកកំពស់នូវសារៈសំខាន់នៃការគោរពទៅតាមក្របខណ្ឌផ្លូវច្បាប់ថ្នាក់ជាតិ ដល់និយោជិត អ្នកតំណាងនិយោជិត និងនិយោជក ជាពិសេសក្នុងពេលដែលមានវិបត្តិសេដ្ឋកិច្ចនេះ។"

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ការប្រកួតប្រជែងនេះគឺបើកទូលាយដល់កម្មករ-កម្មការិនី និង អតីតកម្មករ-កម្មការិនីកាត់ដេរ ដោយឥតគិតថ្លៃ ហើយការទទួលពាក្យចូលរួមប្រកួតនឹងចាប់ទទួលពីថ្ងៃនេះរហូតដល់ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០។ ពាក្យសុំចូលរួមប្រកួតនឹងត្រូវបានចែកជូនដល់រោងចក្រកាត់ដេរ និងអាចរកបាននៅឯការិយាល័យ *គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ឬតាមរយៈគេហទំព័រ www.betterfactories.org ។

កម្មករ-កម្មការិនីកាត់ដេរចំនួន ១២ នាក់ នឹងត្រូវបានជ្រើសរើសដើម្បីប្រកួតប្រជែងជាមួយគ្នានៅចំពោះមុខគណៈកម្មការវិនិច្ឆ័យ នៅក្នុងការផ្សាយផ្ទាល់តាមរលកវិទ្យុមហានគរ FM៩៣.៥។ ការប្រកួតប្រជែងនេះនឹងធ្វើការផ្សាយផ្ទាល់រៀងរាល់ថ្ងៃសៅរ៍ ចាប់ពីថ្ងៃទី ២០ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១០។ ជ័យលាភីចំនួន ៣ រូបនឹងត្រូវប្រកាសនៅថ្ងៃទិវាពលកម្មអន្តរជាតិ គឺថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១០។ ជ័យលាភីលេខ ១ នឹងទទួលបានប្រាក់រង្វាន់ចំនួន ២០០ ដុល្លារ ជ័យលាភីលេខ ២ ចំនួន ១២០ ដុល្លារ និងជ័យលាភីលខ ៣ ចំនួន ៨០ ដុល្លារ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក
លោក ប៊ុន យិញ
អ្នកជំនួយការផ្នែកទំនាក់ទំនងព័ត៌មាន
ទូរស័ព្ទ : ០១២ ៩០ ២៩ ៩០
អ៊ីម៉ែល : ying@ilo.org